**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៣៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីសរុបទំហំ ៤.២៣១ ហិកតា ក្នុងនោះ (១) កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត និង(២)ពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៦៨៩ គ្រួសារ និងផ្តល់សិទ្ធិលើក្បាលដី នៅភូមិគីឡូ១០ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៣៧៣ លខ.កច ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- លិខិតលេខ ២៣៩៨ លខ.កច ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៤.២៣១ ហិកតា ក្នុងនោះ(១)ទំហំ ៣.៩៧៧ ហិកតា ចេញពីព្រៃសម្បទានក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត និង(២) ទំហំ ២៥៤ ហិកតា ពីគម្របព្រៃឈើ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិគីឡូ១០ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៦៨៩ គ្រួសារ នៅភូមិគីឡូ១០ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៦៩០ គ្រួសារ ក្បាលដីចំនួន ៨២៩ ក្បាលដី នៅភូមិតីឡូ១០ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

**មាត្រា ៤.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែធ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យ...២៣៦ អនក្រ.បក...ចុះថ្ងៃទី..០៩..ខែ..[illegible]........ឆ្នាំ២០១៦ ស្ដីពីការកាត់ចេញដី

ចេញពីដីព្រៃសម្បទាន ធីម៉ាស់ វិស្វសលីមីធីត និងតម្រូបព្រៃឈើ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំផ្ទៃដីសរុប ៤.២៣១ ហិកតា

នៅភូមិតីឡា១០ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម សំរាប់ប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្ដែង




ទំនុកតិយានភា

Project UTM Zone 48N, Datum wgs 84

| Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 1381257 | 0568518 | 17 | 1376210 | 0565030 | 34 | 1371199 | 0569322 | 51 | 1371942 | 0569459 | 68 | 1381244 | 0569617 |
| 2 | 1381135 | 0568135 | 18 | 1376087 | 0564969 | 35 | 1370914 | 0569377 | 52 | 1371871 | 0569812 | 69 | 1371979 | 0564187 |
| 3 | 1380850 | 0567893 | 19 | 1375891 | 0565036 | 36 | 1371039 | 0569538 | 53 | 1371917 | 0569866 | 70 | 1372189 | 0563585 |
| 4 | 1380284 | 0567646 | 20 | 1375069 | 0565485 | 37 | 1371221 | 0569510 | 54 | 1372091 | 0569659 | 71 | 1372501 | 0563654 |
| 5 | 1379612 | 0567368 | 21 | 1375615 | 0565730 | 38 | 1371223 | 0569921 | 55 | 1372285 | 0569754 | 72 | 1372527 | 0564097 |
| 6 | 1379379 | 0567375 | 22 | 1375194 | 0566056 | 39 | 1371355 | 0569771 | 56 | 1373652 | 0568570 | 73 | 1372689 | 0564267 |
| 7 | 1378054 | 0567180 | 23 | 1374919 | 0566479 | 40 | 1371380 | 0569633 | 57 | 1374452 | 0567589 | 74 | 1372709 | 0565890 |
| 8 | 1378030 | 0567013 | 24 | 1374778 | 0567181 | 41 | 1371533 | 0569637 | 58 | 1375319 | 0567946 | 75 | 1372320 | 0566578 |
| 9 | 1377802 | 0566908 | 25 | 1371534 | 0568286 | 42 | 1371507 | 0569749 | 59 | 1375946 | 0568328 | 76 | 1372005 | 0566578 |
| 10 | 1377629 | 0566573 | 26 | 1370671 | 0568787 | 43 | 1371390 | 0569980 | 60 | 1375988 | 0568494 | 77 | 1371982 | 0566937 |
| 11 | 1377328 | 0566101 | 27 | 1370753 | 0568857 | 44 | 1371678 | 0569839 | 61 | 1376085 | 0569387 | 78 | 1370034 | 0567237 |
| 12 | 1377072 | 0565554 | 28 | 1370594 | 0569164 | 45 | 1371591 | 0570083 | 62 | 1376146 | 0570631 | 79 | 1371066 | 0566546 |
| 13 | 1377102 | 0565441 | 29 | 1370709 | 0569211 | 46 | 1371749 | 0570022 | 63 | 1377029 | 0573328 | 80 | 1371027 | 0565577 |
| 14 | 1376881 | 0564849 | 30 | 1370873 | 0568971 | 47 | 1371763 | 0569748 | 64 | 1378345 | 0573179 | 81 | 1371111 | 0564893 |
| 15 | 1376817 | 0564880 | 31 | 1371069 | 0568991 | 48 | 1371890 | 0569054 | 65 | 1378739 | 0572989 | 82 | 1371251 | 0564506 |
| 16 | 1376537 | 0564471 | 32 | 1371323 | 0568833 | 49 | 1372133 | 0569123 | 66 | 1379425 | 0572870 | 83 | 1371037 | 0565845 |
|  |  |  | 33 | 1371300 | 0569077 | 50 | 1372034 | 0569231 | 67 | 1380848 | 0572910 | 84 | 1372707 | 0565737 |

563000 566000 569000 572000 575000